00285116

C22/5/25

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ១៧) |
| ដាក់ទៅ: | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: | ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៩ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់លោក អៀង សារី |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 03 / 03 / 2009
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សំណើ *ជាបន្ទាន់* របស់លោក អៀង សារី សុំសេចក្តីបង្គាប់មួយអោយមន្ទីរពេទ្យកាល់ម៉ែត្រ បង្ហាញចេញជាប្រញាប់នូវកំណត់ត្រាវេជ្ជសាស្ត្រនានា និង បញ្ជីឈ្មោះគ្រូពេទ្យដែលព្យាបាល លោក អៀង សារី**

---

**អ្នកដាក់ឯកសារ៖**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / MAR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Tuy

**អ្នកទទួលឯកសារ៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន៍យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

លោក **អៀងសារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី ឬ មេធាវីការពារ") សូមស្នើដោយក្តីគោរពដល់ អង្គបុរេជំនុំជម្រះ សុំបង្គាប់អោយមន្ទីរពេទ្យកាល់ម៉ែត្រ៖ (១) បង្ហាញចេញជាបន្ទាន់នូវរាល់របាយការណ៍វេជ្ជសាស្ត្រទាំងអស់ ដែលទាក់ទងនឹងលោក **អៀងសារី** បន្ទាប់ពីគាត់ត្រូវបានសំរាកព្យាបាលនៅមន្ទីរពេទ្យជាបន្តបន្ទាប់ (២) ផ្តល់បញ្ជីរាយនាមបណ្តាគ្រូពេទ្យទាំងអស់ដែលបានព្យាបាលលោក **អៀងសារី** នៅក្នុងអំឡុងពេលដែលគាត់បានសំរាកព្យាបាលនៅមន្ទីរពេទ្យ រួមមានទាំងព័ត៌មានស្តីពីមុខងាររបស់គ្រូពេទ្យម្នាក់ៗក្នុងការព្យាបាលលោក **អៀងសារី** និង (៣) ផ្តល់នូវព័ត៌មានអំពីសមាជិកនានា រចនាសម្ព័ន្ធ និងអំណាចរបស់ "*គណៈកម្មាធិការ*" ដែលទំនងជាធ្វើការសម្រេចសេចក្តីសំខាន់ៗនានាចំពោះការព្យាបាលដែលធ្វើលោក **អៀងសារី** ។

## I. សេចក្តីសង្ខេបនៃអង្គហេតុ

1. មេធាវីការពារក្តីដាក់ជូននូវសំណើសុំនេះដោយសារមូលហេតុដូចខាងក្រោម៖

   ក. លោក **អៀងសារី** មានសិទ្ធិដាច់ខាត និងពេញលេញទាំងស្រុងដើម្បីទទួលបាននូវឯកសារនានានៃរបាយការណ៍វេជ្ជសាស្ត្រទាំងអស់របស់គាត់

   ខ. លោក **អៀងសារី** មានសិទ្ធិដាច់ខាត និងពេញលេញទាំងស្រុងទទួលបានព័ត៌មានពាក់ព័ន្ធទាំងអស់ថា តើគ្រូពេទ្យណាមួយដែលទទួលខុសត្រូវព្យាបាលគាត់ និងជាពិសេសថា តើនរណាមានតួនាទីក្នុងការសម្រេចសេចក្តីនានាចំពោះការព្យាបាលគាត់ និង

   គ. លោក **អៀងសារី** មានសិទ្ធិដាច់ខាត និងពេញលេញទាំងស្រុងដើម្បីស្នើសុំសេចក្តីបង្គាប់មួយពី អង្គបុរេជំនុំជម្រះ ទៅអោយមន្ទីរពេទ្យកាល់ម៉ែត្រ ក្នុងគោលបំណងដើម្បីទទួលបាននូវរបាយការណ៍វេជ្ជសាស្ត្រនានា ក៏ដូចជាឈ្មោះនិងមុខងាររបស់គ្រូពេទ្យនានាដែលព្យាបាលគាត់ ដែលមិនអាចបដិសេធបាន គឺជាទិន្នន័យការចាំបាច់ចំពោះសេចក្តីសន្និដ្ឋានបន្ថែមទៀតនានាទាក់ទងនឹងសវនាការស្តីពីឃុំខ្លួនបណ្តោះអាសន្ន។

## II. ច្បាប់

2. យោងទៅតាម ក.ស.ច.ស "ការទទួលបាននូវសំណុំឯកសារវេជ្ជសាស្ត្ររបស់ជនជាប់ឃុំនៅមន្ទីរឃុំឃាំង និងមន្ទីរពេទ្យកាល់ម៉ែត្រ គឺជាអ្វីមួយដែលអ្នកជំងឺគ្រប់រូបអាចស្វែងរកត្រូវទទួលបាន"[1] ។

---

[1] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស អនុស្សរណៈអន្តរការិយាល័យ របាយការណ៍វេជ្ជសាស្ត្ររបស់លោក អៀង សារី ចុះថ្ងៃទី ២៥ កុម្ភៈ ២០០៨។

ស្រដៀងគ្នានេះដែរ សហព្រះរាជអាជ្ញាធ្លាប់បានលើកឡើងថា "មេធាវីការពារជនជាប់ចោទនៅដំណាក់កាលឃុំខ្លួនបណ្ដោះអាសន្ន មេធាវីការពារមានសិទ្ធិចូលជួបជនជាប់ចោទនៅគ្រប់ពេលវេលាសមស្របទាំងអស់ និងមានសិទ្ធិពិនិត្យមើលរបាយការណ៍វេជ្ជសាស្ត្ររបស់ជននោះ ទៀតផង[2]"។ បន្ថែមពីនេះ កិច្ចព្រមព្រៀងរវាង មន្ទីរពេទ្យកាល់ម៉ែត្រ និង អ.វ.ត.ក គាំទ្រនូវការបកស្រាយទាំងពីររបស់ ក.ស.ច.ស និង សហព្រះរាជអាជ្ញា ដោយកិច្ចព្រមព្រៀងនេះចែងថា "តាមការស្នើសុំរបស់ជនជាប់ឃុំឃាំងនៅក្នុងមន្ទីរឃុំឃាំងបណ្ដោះអាសន្ន របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា **ភាគី ក [កាល់ម៉ែត្រ]** មានកាតព្វកិច្ចផ្ដល់អោយជនទាំងនោះនូវឯកសារសុខភាព និងព័ត៌មានខាងវេជ្ជសាស្ត្រសមស្របទោះបីជាឯកសារនោះរក្សាទុកនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត្រ ឬមន្ទីរឃុំឃាំងបណ្ដោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"[3]។

3. តាមមើលទៅមិនទំនងជាមានបញ្ញត្តិណាមួយនៃវិធានផ្ទៃក្នុង ដែលទាក់ទងនឹងសិទ្ធិរបស់ជនជាប់ឃុំដើម្បីទទួលបាននូវព័ត៌មានអំពីគ្រូពេទ្យនានាដែលព្យាបាលគាត់ឡើយ ។ ប៉ុន្តែ តាមមាត្រា ២៤ នៃច្បាប់បង្កើត អ.វ.ត.ក ចែងថា "ក្នុងអំឡុងពេលស៊ើបសួរ ជនសង្ស័យនានាត្រូវមានសិទ្ធិដោយគ្មានលក្ខខណ្ឌ ដើម្បីទទួលជំនួយពីមេធាវីការពារក្ដីតាមការជ្រើសរើសរបស់ខ្លួន"។ ដើម្បីអោយសិទ្ធិនេះមានន័យបាន ដាច់ខាតគេត្រូវតែយល់ថាសិទ្ធនេះគ្រប់ដណ្ដប់នូវសិទ្ធិមានមេធាវីដែល<u>មានប្រសិទ្ធិភាព</u>[4]។ សិទ្ធិអាចមានការពាក់ព័ន្ធក្នុងការវាយតម្លៃថា តើវាទំនងជាមានយុត្តិកម្មអ្វីមួយទេចំពោះការណ៍ដែលត្រូវបានគេផ្ដល់អោយនូវព័ត៌មានជាក់លាក់ របាយការណ៍វេជ្ជសាស្ត្រពិសេសនានាដែលធ្វើឡើងគ្រូពេទ្យព្យាបាលដែលត្រូវបានគេតែងតាំង ខណៈដែលជនត្រូវចោទស្ថិតនៅក្រោមកិច្ចការពារនៃ ឬស្ថិតនៅក្រោមសមត្ថកិច្ចរបស់អង្គភាពតុលាការនៃ អ.វ.ត.ក ។

[2] *រឿងក្ដី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំរបស់មេធាវីរបស់លោក អៀង សារី ដើម្បីចូលជួបកូនក្ដីរបស់ខ្លួន និងទទួលរបាយការណ៍វេជ្ជសាស្ត្រ ខណៈពេលដែលស្ថិតនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត្រ ចុះថ្ងៃទី ៣០ ឧសភា ២០០៨ កថាខណ្ឌ ១ ។

[3] កិច្ចព្រមព្រៀងផ្ដល់សេវាសង្គ្រោះបន្ទាន់ និងសេវាវេជ្ជសាស្ត្រផ្សេងៗរវាងមន្ទីរពេទ្យកាល់ម៉ែត្រ និង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("កិច្ចព្រមព្រមព្រៀងរវាង មន្ទីរពេទ្យកាល់ម៉ែត្រ និង អ.វ.ត.ក") សីហា ២០០៨ នៅចំណុច ៧.៦ (គូសបញ្ជាក់បន្ថែម)។

[4] *សូមមើល រឿងក្ដី Artico តទល់នឹង ប្រទេសអ៊ីតាលី* តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ៣០ មេសា ១៩៨០ កថាខណ្ឌ ៣៣ ។

4. ទាក់ទងនឹងយុត្តាធិការទៅលើជនជាប់ឃុំឃាំងខណៈដែលស្ថិតនៅមន្ទីរពេទ្យកាល់ម៉ែត្រ សហព្រះរាជអាជ្ញា បានសន្និដ្ឋានពីមុនថា "[មន្ទីរពេទ្យ]កាល់ម៉ែត្រគឺជាក់ស្តែងជាផ្នែកបន្ថែមមួយនៃមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ហើយលោក **អៀង សារី** នៅតែស្ថិតនៅក្រោមការកម្រិតដូចគ្នាលើសេរីភាពរបស់គាត់ដែលគ្រប់គ្រងគាត់នៅមន្ទីរឃុំឃាំង[5]"។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ អាចចេញដីកាបង្គាប់នានាដោយផ្ទាល់ទៅមន្ទីរពេទ្យកាល់ម៉ែត្រ ទាក់ទងនឹងការព្យាបាលលោក **អៀង សារី** ខណៈពេលដែលគាត់ត្រូវបានគេបញ្ជូនចេញពីមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ទៅកាន់មន្ទីរពេទ្យ។

## III. ឧឡារិករណ៍

### ក. លោក អៀង សារី មានសិទ្ធិផ្ទាល់មុខ និងពេញទីទាំងស្រុងដើម្បីទទួលបាននូវឯកសារនានានៃរបាយការណ៍វេជ្ជសាស្ត្ររបស់គាត់ទាំងអស់

5. ប្រហែលជាមិនមានការមិនយល់ស្របនៅក្នុងចំណោមគូភាគីនានាថា ជនជាប់ឃុំឃាំងមានសិទ្ធិផ្ទាល់មុខ និងពេញលេញទាំងស្រុងដើម្បីអោយគេផ្តល់អោយខ្លួននូវឯកសារនានានៃកំណត់ត្រាវេជ្ជសាស្ត្ររបស់គាត់ទាំងអស់ ។ សិទ្ធិនេះអនុវត្តស្មើគ្នាចំពោះរបាយការណ៍វេជ្ជសាស្ត្រនានាដែលធ្វើឡើងដោយមន្ទីរពេទ្យនានា នៅពេលដែលអ្នកជម្ងឺត្រូវបានគេព្យាបាលនៅទីនោះ ហើយអនុវត្តផងដែរទៅលើរបាយការណ៍ប្រចាំថ្ងៃនានា ដែលរក្សាទុកដោយប្រធាននៃមន្ទីរសុខភាពរបស់ អ.វ.ត.ក ។

6. លោក **អៀងសារី** ត្រូវបានគេឃុំខ្លួនបណ្តោះអាសន្នចាប់តាំងពីថ្ងៃទី ១៤ វិច្ឆិកា ២០០៧ [6]។ ចាប់ពីគាត់ត្រូវបានគេឃុំឃាំង គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យកាល់ម៉ែត្រចំនួន ១០ លើក[7]ផ្សេងៗពីគ្នា។ មានតែរបាយការណ៍វេជ្ជសាស្ត្រចំពោះការស្នាក់នៅព្យាបាលចំនួន ៤ លើកទេ ក្នុងចំណោមទាំង ១០ លើក[8]នេះ ត្រូវបានផ្តល់ជូនដោយមន្ទីរពេទ្យកាល់ម៉ែត្រ ។ ជាលទ្ធផល

---

[5] *អត្ថបទដដែល* កថាខណ្ឌ ២ ។

[6] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាឃុំខ្លួនបណ្តោះអាសន្ន ១៤ វិច្ឆិកា ២០០៧

[7] សូមមើល ឧបសម្ព័ន្ធ ក ដែលរៀបរាប់លំអិតអំពីការស្នាក់នៅព្យាបាលនៅមន្ទីរពេទ្យរបស់លោក អៀង សារី ។

[8] វាប្រហែលចេញពីសំណុំរឿងដែលថា របាយការណ៍វេជ្ជសាស្ត្រទាំង ៤ ដូចតទៅនេះ ដែលត្រូវបានផ្តល់ជូនដោយមន្ទីរពេទ្យកាល់ម៉ែត្រ។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត្រ ចុះថ្ងៃទី ២៨ មករា ២០០៨ ។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស

គ្មានភាគីណាមួយនៅក្នុងសំណុំរឿង ០០២ សូម្បីតែ ក.ស.ច.ស ឬ អង្គបុរេជំនុំជម្រះ ក៏មិនត្រូវគេផ្តល់ជូននូវរាល់ព័ត៌មានចាំបាច់ទាំងអស់ស្តីអំពីលក្ខខណ្ឌសុខភាពរបស់លោក **អៀងសារី** ឡើយ។

7. វេជ្ជបណ្ឌិតរបស់ អ.វ.ត.ក គឺវេជ្ជបណ្ឌិត **ឆេត ផល្លា** បានរក្សានូវការតាមដានជាប់ជាប្រចាំនូវរាល់ជនជាប់ឃុំរបស់ អ.វ.ត.ក ទាំងអស់រួមទាំង លោក **អៀងសារី** ផងដែរ ហើយបានធ្វើនូវរបាយការណ៍សុខភាពជាប្រចាំថ្ងៃ ដែលរៀបរាប់លំអិតនូវស្ថានភាពសុខភាពរបស់គាត់។ របាយការណ៍ប្រចាំថ្ងៃទាំងនេះមិនដែលត្រូវបានគេដាក់បញ្ចូលនៅក្នុងសំណុំរឿងឡើយ ឬមិនត្រូវបានប្រគល់ជូនដាច់ដោយឡែកមកអោយមេធាវីការពារក្តីឡើយ ថ្វីបើមានតម្រូវការដែលមានចែងនៅក្នុងវិធានឃុំឃាំងរបស់ អ.វ.ត.ក[9] និង សំណើសុំជាក់លាក់ និងសមហេតុផលរបស់មេធាវីការពារក្តី ត្រូវបានធ្វើឡើងដោយផ្ទាល់ទៅកាន់មន្ទីរសុខភាពរបស់ អ.វ.ត.ក[10] ក្តី។

## ខ. បើតក្នុងកាលៈទេសៈបច្ចុប្បន្ន លោក អៀង សារី ក៏មានសិទ្ធិទទួលបានផងដែរនូវព័ត៌មានស្តីពីអ្នកណាដែលកំពុងព្យាបាលគាត់ និងអ្នកណាដែលទទួលខុសត្រូវក្នុងការសម្រេចសេចក្តីចំពោះការព្យាបាលគាត់

8. មេធាវីការពារក្តី បានស្នើសុំដើមដំបូងទៅកាន់ អង្គបុរេជំនុំជម្រះ នៅមុនពេលមានសវនាការដេញដោលផ្ទាល់មាត់ទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបន្តថេរៈវេលាឃុំខ្លួនបណ្តោះអាសន្ន ដែលត្រូវធ្វើនៅថ្ងៃទី ២៦ កុម្ភៈ ២០០៩ ដើម្បីសុំអោយកោះអញ្ជើញ "រាល់គ្រូពេទ្យទាំងអស់នៅ

---

របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត្រ ចុះថ្ងៃទី ៩ កុម្ភៈ ២០០៨ ។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត្រ ចុះថ្ងៃទី ៧ មីនា ២០០៨ ។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត្រ ចុះថ្ងៃទី ២៤ ធ្នូ ២០០៨ ។

[9] វិធានសម្រាប់គ្រប់គ្រងការឃុំខ្លួនជន ដែលរង់ចាំការជំនុំជម្រះ ឬ ប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានឃុំឃាំងរបស់ អ.វ.ត.ក") ត្រង់វិធាន ៥.៧.១ ចែងថា "ព័ត៌មានដែលមាននៅក្នុងសំណុំឯកសារសុខភាពរបស់ជនជាប់ឃុំ ... មិនត្រូវផ្សព្វផ្សាយទៅបុគ្គលណាម្នាក់លើកលែងតែៈ សាម៉ីខ្លួនជនជាប់ឃុំ ក្រុមមេធាវីដែលបានចាត់តាំងសម្រាប់ជនជាប់ឃុំនោះ ដោយមានការឯកភាពពីសាម៉ីខ្លួនជនជាប់ឃុំនោះ" (គូសបញ្ជាក់បន្ថែម)។

[10] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ចម្លើយតបទៅនឹងសំណើសុំរបស់មេធាវី អាងឧត្តម មេធាវីការពារក្តីរបស់លោក អៀង សារី ចុះថ្ងៃទី ២០ កុម្ភៈ ២០០៨។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំបញ្ជីនៃកំណត់ត្រាវេជ្ជសាស្ត្រនានារបស់លោក អៀង សារី ចុះថ្ងៃទី ២៩ មករា ២០០៨។

មន្ទីរពេទ្យកាល់ម៉ែត្រ ដែលបានទទួលខុសត្រូវពិនិត្យ និងព្យាបាលលោក **អៀងសារី**" [11]។ អង្គបុរេជំនុំជម្រះ បានបដិសេធនូវសំណើសុំនេះ ប៉ុន្តែបានអនុញ្ញាតអោយមេធាវីការពារក្តី "លើកឡើងនូវទឡ្ហីករណ៍នានាថ្មីនាអំឡុងពេលសវនាការលើកក្រោយ [ហើយ] ធ្វើពាក្យសុំរបស់ខ្លួនសារជាថ្មីចំពោះចំនុចនេះ ដោយសំអាងថាវាធម្មជាតិជាក់លាក់របស់ពាក្យសុំនេះ" [12]។ នៅក្នុងសេចក្តីសម្រេចលើកក្រោយរបស់ខ្លួននេះស្តីពីសំណើសុំផ្សេងៗ ដែលដាក់ស្នើជូននាអំឡុងពេលសវនាការដេញដោលផ្ទាល់មាត់ អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថា "គ្មានពាក្យសុំដែលកាន់តែមានលក្ខណៈជាក់លាក់បន្ថែមទៀតដែលត្រូវបានគេដាក់ជូន ដូចត្រូវបានស្នើដោយ អង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី ២៣ កុម្ភៈ ២០០៨ ឡើយ"[13] ។ ដើម្បីបំពេញនូវតម្រូវការអោយមានសំណើសុំដែលលំអិត និងជាក់លាក់បន្ថែមទៀត ទៅកាន់ អង្គបុរេជំនុំជម្រះ មន្ទីរពេទ្យកាល់ម៉ែត្រ ដាច់ខាតត្រូវតែផ្តល់អោយមេធាវីការពារក្តី នូវព័ត៌មានកាន់តែច្រើនថែមទៀត ច្រើនជាងអ្វីដែលបានផ្តល់អោយនៅក្នុងរបាយការណ៍វេជ្ជសាស្ត្រទាំងបួន ដែលបង្ហាញតាំងពីមុននោះមក។ ជាសារវ័ន្ត ព័ត៌មាននេះដាច់ខាតត្រូវតែគេផ្តល់អោយមេធាវីការពារក្តីដើម្បីអាចតំណាងការពារក្តីលោក **អៀងសារី** អោយមានប្រសិទ្ធិភាព ដូចដែលបានធានាដោយមាត្រា ២៤ នៃច្បាប់បង្កើតសាលាក្តី[14] ។

9. ជំហានដំបូងដើម្បីផ្តល់នូវព័ត៌មានកាន់តែជាក់លាក់ថែមទៀតនោះគឺ ការពិតត្រូវតែលាតត្រដាងនូវរបាយការណ៍វេជ្ជសាស្ត្រនានាដែលនៅសេសសល់ អំពីការស្នាក់នៅព្យាបាលរបស់លោក **អៀង**

---

[11] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ១៧) សំណើរបស់លោក អៀង សារី សុំអោយកោះអញ្ជើញអ្នកជំនាញវេជ្ជសាស្ត្រ ដើម្បីអោយផ្តល់ភស្តុតាងនាពេលសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ៩ កុម្ភៈ ២០០៨ ទំព័រទី ៥ ។

[12] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ១៧) សេចក្តីសម្រេចលើសំណើសំណើរបស់លោក អៀង សារី សុំអោយកោះអញ្ជើញអ្នកជំនាញវេជ្ជសាស្ត្រ ដើម្បីអោយផ្តល់ភស្តុតាងនាពេលសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ២៣ កុម្ភៈ ២០០៨ កថាខណ្ឌ ១៤ ។

[13] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ១៧) សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចផ្ទាល់មាត់ នាថ្ងៃទី ២៦ កុម្ភៈ ២០០៨ ស្តីពីសំណើសុំនានាដែលដាក់ចំពោះមុខអង្គបុរេជំនុំជម្រះ នាពេលសវនាការដេញដោលផ្ទាល់មាត់ដែលធ្វើឡើងនាថ្ងៃដដែលនេះ សេចក្តីសម្រេចចុះថ្ងៃទី ២៧ កុម្ភៈ ២០០៨ កថាខណ្ឌ ៤ ។

[14] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាមួយនឹងការដាក់បញ្ចូលនូវការធ្វើវិសោធនកម្មដែលត្រូវបានប្រកាសអោយប្រើនាថ្ងៃទី ២៧ តុលា ២០០៤ (នស/រកម/១០០៤/០០៦) ។

**សារី** នៅមន្ទីរពេទ្យកាល់ម៉ែត្រ ដូចមានរៀបរាប់នៅខាងលើ។ របាយការណ៍នីមួយៗមានរាយនាមគ្រូពេទ្យនានាដែលទទួលខុសត្រូវចងក្រងរបាយការណ៍នោះ[15]។ ជាមួយព័ត៌មាននេះ មេធាវីការពារក្តី អាចពិនិត្យពិច័យថា គ្រូពេទ្យណាមួយដែលមានជាប់ពាក់ព័ន្ធច្រើនជាងគេក្នុងការព្យាបាលលោក **អៀងសារី**[16]។

10. នៅក្នុង និងអំពីព័ត៌មាននេះខ្លួនឯង គឺមិនគ្រប់គ្រាន់ដើម្បីអនុញ្ញាតអោយមេធាវីការពារក្តី ដើម្បីធ្វើអោយជាក់ច្បាស់ថា គ្រូពេទ្យណាមួយនៃគ្រូពេទ្យទាំងនេះដែល មេធាវីការពារក្តី មានបំណងនឹងអោយគេកោះអញ្ជើញដើម្បីផ្តល់ភស្តុតាងនាសវនាការដេញដោលផ្ទាល់មាត់ដែលគ្រោងធ្វើនៅថ្ងៃទី ២ មេសា ២០០៨។ ព័ត៌មានបន្ថែមទៀតថា គ្រូពេទ្យណាមួយទទួលខុសត្រូវចំពោះផ្នែកណាខ្លះនៃការព្យាបាល ដាច់ខាតត្រូវតែផ្តល់ជូនផងដែរ ធ្វើដូច្នេះដើម្បីអោយគេស្នើសុំអោយគ្រូពេទ្យដែលត្រឹមត្រូវដើម្បីមកផ្តល់ភស្តុតាង។ ឧទាហរណ៍ បើសិនជា អង្គបុរេជំនុំជម្រះ ទទួលយកថាភស្តុតាងផ្ទាល់មាត់ស្តីពីលក្ខខណ្ឌសុខភាពរបស់លោក **អៀងសារី** ត្រូវបានអនុញ្ញាត វាប្រាកដណាស់ថា អ្នកជំនាញបេះដូងរបស់គាត់នឹងត្រូវបានគេកោះអញ្ជើញដើម្បីអោយផ្តល់ភស្តុតាង ជាជាងកោះហៅគ្រូពេទ្យដែលជាអ្នកទទួលខុសត្រូវចំពោះជម្ងឺផ្សេងទៀវិញ។

11. គួរអោយចាប់អារម្មណ៍ផងដែរ នៅក្នុងការទំនាក់ទំនងរបស់ខ្លួននាពេលថ្មីៗនេះជាមួយបុគ្គលិកនៃមន្ទីរពេទ្យកាល់ម៉ែត្រ មេធាវីការពារក្តីបានយល់ដឹងថា[17]មាន *"គណៈកម្មាធិការ"* នៅមន្ទីរពេទ្យ

---

[15] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត្រ ចុះថ្ងៃទី ២៤ ធ្នូ ២០០៨ ដែលរាយនាមសាស្ត្រាចារ្យ ញ៉ែម សាអឿន វេជ្ជបណ្ឌិត ព្រំ វិសេស និងវេជ្ជបណ្ឌិត លីវ ឈិញ ជាគ្រូពេទ្យដែលបានចងក្រងនូវរបាយការណ៍នេះ។

[16] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត្រ ចុះថ្ងៃទី ២៨ មករា ២០០៨ ដែលរបាយការណ៍នេះត្រូវបានធ្វើឡើងដោយក្រុមដែលរួមមានសាស្ត្រាចារ្យ ញ៉ែម សាអឿន វេជ្ជបណ្ឌិត ព្រំ វិសេស និងវេជ្ជបណ្ឌិត លីវ ឈិញ ជាគ្រូពេទ្យដែលបានចងក្រងនូវរបាយការណ៍ថ្ងៃទី ២៤ ធ្នូ ២០០៨។ *សូមមើលផងដែរ រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត្រ ចុះថ្ងៃទី ៩ កុម្ភៈ ២០០៨ ។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត្រ ចុះថ្ងៃទី ៧ មីនា ២០០៨ ដែលរបាយការណ៍ទាំងពីរនេះត្រូវបានធ្វើឡើងដោយសាស្ត្រាចារ្យ ញ៉ែម សាអឿន ។

[17] នៅពេលដែលលោក អៀង សារី ត្រូវបានសំរាកព្យាបាលនាពេលថ្មីៗនេះនៅមន្ទីរពេទ្យកាល់ម៉ែត្រ មេធាវីការពារក្តីបានប៉ុនប៉ងចូលជួបសួរសុខទុក្ខគាត់នៅថ្ងៃទី ២៥ កុម្ភៈ ២០០៩ ប៉ុន្តែត្រូវបានបដិសេធដោយអ្នកយាមនានាដែលឈរជើងនៅខាងក្រៅទ្វារ

ដែលហាក់ដូចជាធ្វើការសម្រេចសេចក្តីចុងក្រោយទៅលើការព្យាបាល ការទទួលស្នាក់នៅព្យាបាល និងការបញ្ជូនចេញពីមន្ទីរពេទ្យរបស់ លោក **អៀងសារី** ។ នៅក្នុងស្ថាប័នដែលស្រពេចស្រពិលនេះ វាមិនមានភាពច្បាស់លាស់ច្រើនចំពោះថា នរណាគឺជាសមាជិកនៃ*គណៈកម្មាធិការ* នេះ ហើយថា តើវាគ្រាន់តែរួមបញ្ចូលនូវក្រុមគ្រូពេទ្យនានាដែលពាក់ព័ន្ធក្នុងការព្យាបាលលោក **អៀងសារី** នៅពេលកំណត់ណាមួយជាក់លាក់ ឬក៏មានមនុស្សបន្ថែមទៀត ដូចជា ប្រធានមន្ទីរពេទ្យជាដើម។ ការផ្តល់នូវព័ត៌មានដែលមានតម្លាភាពស្តីពីសមាជិកនាន រចនាសម្ព័ន្ធ និងអំណាចរបស់ *គណៈកម្មាធិការ* ដែលធ្វើសេចក្តីសម្រេចទាក់ទងនឹងលោក **អៀងសារី** តាមរយៈគ្រូពេទ្យដែលព្យាបាលដូចបានថ្លែងខាងលើនៅក្នុងរបាយការណ៍នានារបស់មន្ទីរពេទ្យ អាចនឹងជាជំនួយដ៏ធំក្រៃលែងដល់មេធាវីការពារក្តី នៅក្នុងការរៀបចំនូវសំណើដែលលំអិត និងជាក់លាក់អំពីថា តើគ្រូពេទ្យណាមួយដែលនឹងត្រូវកោះអញ្ជើញដើម្បីផ្តល់ភស្តុតាងផ្ទាល់មាត់។

12. ជាចុងក្រោយ គេគួរសង្កត់ធ្ងន់ថា ព័ត៌មានដែលស្នើសុំនេះ <u>នឹងមិនបង្កើតនូវបន្ទុករដ្ឋបាលដែលមិនចាំបាច់មកលើមន្ទីរពេទ្យ ឬ រំលោភសិទ្ធិតាមសន្ទតនៃការសម្ងាត់របស់មន្ទីរពេទ្យឡើយ</u>។ ការពិត វានឹងធ្វើផ្ទុយពីនេះទៅវិញទេ ។ វានឹងកាត់បន្ថយនូវចំនួនគ្រូពេទ្យនានាមកពីមន្ទីរពេទ្យកាល់ម៉ែត្រ ដែលត្រូវគេកោះអញ្ជើញដើម្បីផ្តល់ភស្តុតាង ហើយការងាររបស់អ្នកទាំងនោះនៅមន្ទីរពេទ្យនឹងមិនត្រូវបានរំខានឡើយ។ ព័ត៌មាននេះនឹងទាក់ទងត្រឹមតែការព្យាបាលលោក **អៀងសារី** ដូច្នេះហើយនឹងមិនតម្រូវអោយលាតត្រដាងនូវព័ត៌មានផ្សេងទៀតនានា ដែលលោក **អៀងសារី** មិនមានសិទ្ធិទទួលបាននោះឡើយ។ ទាក់ទងនឹង អង្គបុរេជំនុំជម្រះ វានឹងធានាថា ពេលវេលារបស់តុលាការដែលនៅសេសសល់សម្រាប់ អង្គបុរេជំនុំជម្រះ នឹងមិនត្រូវចំណាយចោលឥតប្រយោជន៍តាមរយៈការកោះហៅគ្រូពេទ្យដែលមិនទាំងមានចំណេះដឹង ឬមិនមានទំនួលខុសត្រូវចំពោះលក្ខខណ្ឌសុខភាពជាក់ស្តែងដែលមេធាវីការពារក្តីមានបំណងចោទសួរអ្នកទាំងនោះឡើយ។

## គ. កាយវិការរារាំងរបស់មន្ទីរពេទ្យកាល់ម៉ែត្រទៅសំណើសុំព័ត៌មាននានាទាក់ទងនឹងលោក អៀង សារី តម្រូវអោយគេត្រូវចេញនូវសេចក្តីបង្គាប់មួយរបស់តុលាការ

---

បន្ទប់មន្ទីរពេទ្យរបស់គាត់ ។ មេធាវីការពារក្តីបានទាក់ទងលោក រីឆាដ រ៉ូចើ ដែលជាប្រធានអង្គភាពគាំពារការការពារក្តីដើម្បីអោយដឹងបើសិនជាគាត់អាចស្វែងរកព័ត៌មានបន្ថែមទៀតបាន ។ គាត់បានប្រាប់មកមេធាវីការពារក្តីថា "<u>*គណៈកម្មាធិការ*</u>" ឥឡូវហ្នឹងកំពុងជាប់ប្រជុំ ដូច្នេះហើយមិនអាចទាក់ទងដើម្បីអោយដឹងថា តើគាត់អាចនឹងផ្តល់ការអនុញ្ញាតដល់មេធាវីការពារក្តីដែរឬទេ។ វាមិនមានលក្ខណៈច្បាស់លាស់ថា នរណាគឺជាសមាជិកនៃគណៈកម្មាធិការនេះ។

13. មន្ទីរពេទ្យកាល់ម៉ែត្រ បានរាំងខ្ទប់ជាបន្តបន្ទាប់ និងដោយចេតនាមិនអោយមេធាវីការពារក្តីដែលប៉ុនប៉ងសួរសុខទុក្ខលោក **អៀងសារី** នៅពេលដែលគាត់ត្រូវស្នាក់នៅព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ[18] ។ វេជ្ជបណ្ឌិត **នេត ផល្លា** ជាវេជ្ជបណ្ឌិតរបស់ អ.វ.ត.ក ដែលស្ថិតនៅក្រោមអំណាចរបស់មន្ទីរពេទ្យកាល់ម៉ែត្រ ក៏បានបដិសេធផងដែរនូវសំណើសុំដ៏សមហេតុផល និងជាក់លាក់របស់មេធាវីការពារក្តី ដើម្បីទទួលបាននូវកំណត់ត្រាវេជ្ជសាស្ត្រប្រចាំថ្ងៃនានាស្តីពីលោក **អៀងសារី**[19] ថ្វីបើមានការអះអាងរបស់ ក.ស.ច.ស ថា “ការទទួលបាននូវសំណុំឯកសារវេជ្ជសាស្ត្ររបស់ជនជាប់ឃុំនៅមន្ទីរឃុំឃាំង គឺជារឿងធម្មតាដែលអ្នកជំងឺគ្រប់រូបត្រូវទទួលបាន”[20]ក៏ដោយ។

14. បន្ទាប់ពីការពិចារណានូវឥរិយាបទរារាំង និងព្រហើនដែលបង្ហាញឡើងជាបន្តបន្ទាប់ដោយមន្ទីរពេទ្យកាល់ម៉ែត្រ ទាក់ទងទៅនឹងទាំង មេធាវីការពារក្តី និង ក.ស.ច.ស មានតែដីកាបង្គាប់របស់តុលាការទេដោយភ្ជាប់ជាមួយនឹងកាលបរិច្ឆេទកំណត់សំរាប់អោយ មន្ទីរពេទ្យកាល់ម៉ែត្រគោរពតាម គឺពិតជាបណ្តាលអោយមានព័ត៌មានដែលស្នើសុំនឹងត្រូវផ្តល់ជូនជាពុំខាន ។ វាក៏អនុញ្ញាតផងដែរដល់ មេធាវីការពារក្តី ដើម្បីដាក់សំណើជាបន្តបន្ទាប់សុំអោយមានការពិនិត្យដោយគ្រូពេទ្យជាក់លាក់ដោយផ្អែកទាំងស្រុងលើសំណុំឯកសារវេជ្ជសាស្រ្តរបស់ លោក **អៀងសារី** ដោយគ្រប់គ្រាន់នៅមុនសវនាការដែលដាក់កាលបរិច្ឆេទនាថ្ងៃទី ២ មេសា ២០០៩ ដើម្បីអោយសំណើសុំនេះនឹងត្រូវបានដោះស្រាយនៅមុនពេលមានសវនាការនេះ។

---

[18] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស លិខិតទៅ ក.ស.ច.ស មានចំណងជើងថា សំណើរបស់មេធាវី អៀង សារី សុំជួបលោក អៀង សារី សុំពិនិត្យមើលកំណត់ហេតុវេជ្ជសាស្ត្ររបស់គាត់ និងសុំជួបជាមួយគ្រូពេទ្យដែលព្យាបាលគាត់ជាបន្ទាន់ និងដោយសេរី នៅពេលគាត់ស្ថិតនៅក្រោមការព្យាបាលនៅមន្ទីរពេទ្យ ចុះថ្ងៃទី ៤ សីហា ២០០៨ ។

[19] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ចម្លើយតបទៅនឹងសំណើរបស់មេធាវី អាង ឧត្តម មេធាវីការពារក្តីលោក អៀង សារី ចុះថ្ងៃទី ២០ កុម្ភៈ ២០០៨។ ព័ត៌មាននេះត្រូវបានស្នើសុំដោយមេធាវីការពារក្តីបីសប្តាហ៍មុន ។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំបញ្ជីកំណត់ត្រាវេជ្ជសាស្ត្ររបស់លោក អៀង សារី ចុះថ្ងៃទី ២៩ មករា ២០០៨ ។

[20] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស អនុស្សារណៈអន្តរការិយាល័យ ស្តីពីរបាយការណ៍វេជ្ជសាស្ត្រនានារបស់លោក អៀង សារី ចុះថ្ងៃទី ២៥ កុម្ភៈ ២០០៨ ។

## IV. សេចក្ដីសន្និដ្ឋាន និងសំណូមពរ

អាស្រ័យដោយហេតុផលដូចមានថ្លែងនៅទីនេះ មេធាវីការពារក្ដីសូមស្នើដោយក្ដីគោរពដល់ អង្គបុរេជំនុំជម្រះ សុំអោយចេញដីកាបង្គាប់មួយដល់ មន្ទីរពេទ្យកាល់ម៉ែត្រ ដើម្បីផ្ដល់នូវព័ត៌មានដូចខាងក្រោមនេះ ត្រឹមថ្ងៃទី **១៣ មីនា ២០០៩**៖

(១) បណ្ដាកំណត់ត្រាវេជ្ជសាស្ត្រទាំងអស់ដែលទាក់ទងនឹងលោក **អៀងសារី** ចំពោះការស្នាក់ព្យាបាលជាបន្តបន្ទាប់នៅមន្ទីរពេទ្យ និងចំពោះកំណត់ត្រាប្រចាំថ្ងៃនានារបស់លោក **នេត ផល្លា**

(២) បញ្ជីឈ្មោះគ្រូពេទ្យទាំងអស់ដែលបានព្យាបាលលោក **អៀងសារី** នាអំឡុងពេលការស្នាក់នៅព្យាបាលរបស់គាត់នៅមន្ទីរពេទ្យ រួមទាំងព័ត៌មានស្ដីពីតួនាទីជាក់លាក់នៃគ្រូពេទ្យនីមួយៗ នៅក្នុងការព្យាបាល លោក **អៀងសារី** និង

(៣) ព័ត៌មានអំពីសមាជិកនានា វចនាសម្ព័ន្ធ និងអំណាចរបស់ *គណៈកម្មាធិការ* តាមរយៈគ្រូពេទ្យព្យាបាលនានា ដែលបានរៀបរាប់នៅក្នុងរបាយការណ៍នានារបស់មន្ទីរពេទ្យដែលប្រហែលជាធ្វើការសម្រេចសេចក្ដីចំពោះការព្យាបាល លោក **អៀងសារី** ។

សូមអង្គបុរេជំនុំជម្រះទទួលយកសំណើសុំនេះដោយក្ដីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **៣ ខែមីនា** ឆ្នាំ **២០០៩**

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**អាង ឧត្ដម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**